មហាអយ្យការសាលាឧទ្ធរណ៍

លេខ ៣៥៦-២០០៣

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គព្រះរាជអាជ្ញា មហាអយ្យការសាលាឧទ្ធរណ៍

## ជូនមកលោកព្រះរាជអជ្ញាតុលាការខេត្ត ក្រុង

***កម្មវត្ថុ:*** អំពីភារៈកិច្ចចង្អុលភស្តុតាង ។

តាមការសង្កេតលើសំណុំរឿងព្រហ្មទណ្ឌប្តឹងឧទ្ធរណ៍ ខ្ញុំបានកត់សម្គាល់ឃើញមានការខ្វះខាតក្នុងភារៈកិច្ចមួយដែលជាផលវិបាកធ្ងន់ធ្ងរក្នុងការទទួលខុសត្រូវរបស់អស់លោកជាអយ្យការ ជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងក្នុងការចោទប្រកាន់គឺការចង្អុលភស្តុតាង ។

លោកព្រះរាជអាជ្ញា លោកព្រះរាជអាជ្ញារងបានធ្វើដីកាសន្និដ្ឋានចោទប្រកាន់សុំអោយចៅក្រមស៊ើបសួរ ឬធ្វើដីកាសន្និដ្ឋានស្ថាពរសុំអោយបញ្ជូនជនល្មើសទៅតុលាការជំនុំជម្រះ ដីកាសន្និដ្ឋានទាំងនេះត្រូវតែធ្វើសេចក្តីសំយោគផ្តេកផ្តួលលើភស្តុតាងជាដរាប ភស្តុតាងទាំងនេះត្រូវជាភស្តុតាងទាក់ទងនិងធាតុផ្សំនៃបទល្មើសដែលមានធាតុសម្ភារៈដែលជាអំពើស្តែងចេញជាការប្រព្រឹត្តអំពើជាក់ស្តែងឬក៏អាចជាអំពើអសកម្មដែរ ធាតុចេតនាក្នុងការប្រព្រឹត្តិបទល្មើស ធាតុបញ្ញត្តិច្បាប់ចែងអំពីបទល្មើស អំពីទោស និងអាចមានធាតុផ្សំផ្សេងទៀត ទៅតាមគោលការណ៍ នៃច្បាប់បានចែងហើយនិងត្រូវគិតអំពីស្ថានទម្ងន់ ស្ថានសម្រាលផងដែរ សរុបសេចក្តីទៅអយ្យការត្រូវចង្អុលភស្តុតាងជាដ៏រាបពីព្រោះអយ្យការជាអ្នកចោទប្រកាន់ ជាភាគីដើមដែលច្បាប់បានប្រគល់អំណាចជូន ដូចជាមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញ មាត្រា២, ៣, ៤, ៨,៥៩ និងតទៅនៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ត្រូវមានភស្តុតាងជាបង្អែកជាមូលដ្ឋានសំអាងដើម្បីចៀសវាងរបៀបចោទប្រកាន់ដោយរំលោភអំណាច ។ អាចចោទប្រកាន់ ស្រ័យដោយយកភស្តុតាងសព្វគ្រប់នេះមានគោលដៅជាចម្បង គឺសុំឲ្យតុលាការព្រហ្មទណ្ឌផ្តន្ទាឲ្យជនល្មើសដែលត្រូវទទួលខុសត្រូវជាប់ពន្ធនាគារ ត្រូវកែប្រែគំនិតមាយាទ ដើម្បីក្លាយជាប្រជាពលរដ្ឋល្អ អាចត្រឡប់ទៅរួមរស់ក្នុងសង្គមវិញក្នុងពេលអនាគត ។

ដូច្នេះ ដើម្បីអាចមានភស្តុតាង ធួនល្មម (ពាក្យប្រើក្នុងដីកា ឬសាលក្រម) នៅពេលសវនាការនៃតុលាការហើយទទួលថាធួនល្មមមែននោះ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងដែលជាអ្នកទទួលភារៈកិច្ចត្រូវស្វះស្វែង តាំងពីដំណាក់កាលនៃអំពើប្រព្រឹត្តភ្លាមៗ ដែលអាចអោយតម្លៃជាអំពើជាក់ស្តែង(កំណត់ហេតុត្រូវតែឆ្លុះបញ្ចាំងលក្ខខ័ណ្ឌជាក់ស្តែងផង) ហើយអន្តរាគមរបស់មន្ត្រីនគរបាលយុត្តិធម៌ មានសារៈសំខាន់ណាស់ ចំណែកឯវត្តមានរបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មានសារៈសំខាន់ដែរ ដែលមានភារៈកិច្ចដឹកនាំមន្ត្រីនគរបាលដទៃទៀត តាមបញ្ញត្តិមាត្រា៣៦ នៃច្បាប់នីតិវិធីព្រហ្មខណ្ឌ ដើម្បីប្រមូលភស្តុតាងសំណៅភស្តុតាងផ្សេងៗពាក់ព័ន្ធនឹងជនល្មើសដើម្បីការពារកុំឲ្យបាត់កុំអោយបំបាត់ កុំអោយវិនាសទៅវិញ ឬបំផ្លាញទៅវិញ ហើយភស្តុតាង និងសំណៅភស្តុតាងទាំងនេះមានដូចជាអាវុធ កាំភ្លើង គ្រាប់កាំភ្លើង កាំបិត ពូថៅ ប្រដាប់ប្រដាវត្ថុផ្សេងៗ ស្នាមដានជើង ខ្ចៅដៃ ឈាម ទឹកកាម ទឹកមាត់ ទឹកភ្នែក សក់ រោម ស្បែកសក់។ល ។ ដែលនឹងត្រូវពង្រឹង និងស្វែងរកទំនាក់ទំនងជាមួយជនល្មើសដោយអ្នកបច្ចេកទេស នៅពេលបន្តបន្ទាប់ក្នុងដំណាក់កាលស៊ើបអង្កេត ដោយចៅក្រមព្រមទាំងឃាត់ខ្លួនជនល្មើសដែលពាក់ព័ន្ធ។ខ្ញុំសូមឆ្លៀតទាក់ទាញអារម្មណ៍ថា លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងត្រូវប្រុងប្រយ័ត្ននិងគ្រោងថា នៅដំណាក់កាលផ្សេងៗទៅអនាគតអាចមានការប្រើមធ្យោបាយ កែក្រឡះសភាពដើមនៃភស្តុតាងចង្អុលភស្តុតាំងផ្ទុយ ។

ដូច្នេះភស្តុតាងត្រូវតែរឹងមាំ ឬស្វែងរកចំណុចរឹងមាំមិនអាចអោយកែប្រែបាន ដូច្នេះភស្តុតាងដែលប្រមូលបានដែលស្រាវជ្រាវរកឃើញជាបន្តបន្ទាប់ត្រូវតែលោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ការពារតាមកាពារនៅគ្រប់

ដំណាក់កាល ទោះជាក្នុងពេលសវនាការនៃតុលាការ ក៏ត្រូវតែការពារដែរដោយគិតថាភស្តុតាងភាគច្រើនមានតម្លៃរហូតដល់មានភស្តុតាងផ្ទុយ ដូចមានចែងបញ្ជាក់ក្នុងបញ្ញត្តិមាត្រា៤២ នីតិវិធីព្រហ្មទណ្ឌថ្ងៃ១៣-០១-៩៣ និងមាត្រា ២៤ នីតិវិធីអន្តរកាល ហើយភស្តុតាងផ្ទុយ ជាភស្តុតាងប្រភេទជាភស្តុតាងពុំមែនជាចម្លើយបដិសេធរបស់ជនល្មើសពេលសវនាការ ពេលចម្លើយដែលមិនត្រូវទទួលស្គាល់ជាភស្តុតាងផ្ទុយគ្រប់គ្រាន់បាន ។

ចម្លើយទាំងអស់នេះមានតម្លៃជាព័ត៌មាន ឬក៏លំនាំដើមដើម្បីអាចស្វែងរកភស្តុងតាងផ្ទុយប៉ុណ្ណោះ ពីព្រោះមិនប្រកាន់ដូច្នេះទេនោះ មានការទាត់ចោលលទ្ធផលស៊ើបអង្កេតពីដំបូងនិងនៅដំណាក់កាល ចៅក្រមស៊ើបអង្កេតហើយគិតថាគ្មានតម្លៃទុកជាអសាឥតការ ហើយមកគិតតែអំពីចម្លើយពេលសវនាការចុងក្រោយនេះជាមានតម្លៃប៉ុណ្ណោះ ។

ម្យ៉ាងទៀត ខ្ញុំសូមលោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងផ្តល់តម្លៃដល់ការងារចុះស៊ើបអង្កេតជាមួយនគរបាលយុត្តិធម៌នៅពេលមានបទល្មើសព្រហ្មទណ្ឌបានត្រូវប្រព្រឹត្តក្នុងន័យជៀសវាងប្រកាន់តរិយាបទ បណ្តោយអោយនគរបាលយុត្តិធម៌ដើរតួនាទីជាអយ្យការជំនួសចំណែកខ្លួនឯងជ្រើសរើសដើរតួនាទីជាទីងមោង ដោយយកលេសថាអយ្យការគ្មានមធ្យោបាយធ្វើដំណើរ និងថវិកាដើម្បីបំពេញការងារ ។

ខ្ញុំសូមឆ្លៀតទាក់ទាញអារម្មណ៍លោកព្រះរាជអាជ្ញារងខ្លះ ពេលចុះស៊ើបអង្កេតជាមួយមន្ត្រីនគរបាលយុត្តិធម៌កុំឆ្លៀតគៃបំបាត់នូវវត្ថុតាងដកហូត ជាប្រយោជន៍ផ្ទាល់ខ្លួនដែលជាអំពើប្រព្រឹត្តបទល្មើស ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣

**អគ្គព្រះរាជអាជ្ញា**

**ហង់ រ៉ូ រ៉ាគេន**

ចម្លងជូន

-ឯកឧត្តម លោកជំទាវក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-ឯកឧត្តម លេខាធិការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ដើម្បីជ្រាបជាព័ត៌មាន